**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៥. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសម្របសម្រួលទទួលជំនួយរបស់រដ្ឋាភិបាលគុយវ៉ែត សំរាប់អភិវឌ្ឍន៍មជ្ឈមណ្ឌលឥស្លាមកម្ពុជា វិហារ និងសាលារៀន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការមួយ ដើម្បីសម្របសម្រួលជំនួយផ្នែកសាសនា និងមនុស្សធម៌ ពីប្រទេសគុយវ៉ែត ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម មិន ឃិន | រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា | ប្រធាន |
| ២-ឯកឧត្តម អូស្មាន ហាស្សាន់ | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣-ឯកឧត្តម វ៉ាន់ ម៉ាត់ | ប្រធានសមាគមឥស្លាមកម្ពុជា | អនុប្រធាន |
| ៤-ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា | ទីប្រឹក្សារាជរដ្ឋាភិបាល | អនុប្រធាន |
| ៥-ឯកឧត្តម ហ្សាការីយ៉ា អាដាម | រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ៦-ឯកឧត្តម ស្លាន ទៀត | អនុប្រធានអង្គការមូលនិធិអភិវឌ្ឍន៍មុស្លីមកម្ពុជា | សមាជិក |
| ៧-ឯកឧត្តម សុះ មុះសិន | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៨-ឯកឧត្តម សឹម សុខព្រី | អភិបាលរងខេត្តកំពង់ចាម | សមាជិក |
| ៩-ឯកឧត្តម ឡា ឡៃ | មេបញ្ជាការកងរាជអាវុធហត្ថខេត្តតាកែវ | សមាជិក |

www.pheakdeylaw.com

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចសម្របសម្រួលទទួលថវិកាជំនួយរបស់រដ្ឋាភិបាលគុយវ៉ែត សំរាប់អភិវឌ្ឍន៍មជ្ឈមណ្ឌលឥស្លាមកម្ពុជា វិហារ និងសាលារៀន ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ